សុន្ទរកថារបស់ **ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព
របស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយឥតសំណង
សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន
១ មិនា ២០១៦

- **សូមគោរពលោកស្រី តាកាហាស៊ី អាគីមិ នាយិការអង្គការ FIDR**
- **សូមគោរពលោក សាកូ ណាហ្គាតូស៊ី ប្រធានតំណាងអង្គការសកម្មភាពកំចាត់មីនជប៉ុន JMAS**
- **សូមគោរព អស់លោក លោកស្រី!**

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយ ដើម្បីប្រារព្ធពិធីចុះហត្ថលេខាផ្តល់ជំនួយសម្រាប់ "គម្រោងសន្តិសុខស្បៀង និងអាហាររូបត្ថម្ភ ដំណាក់កាលទី៣ ប្រចាំខេត្តកំពង់ឆ្នាំង" ផ្តល់ជូនដល់អង្គការFIDR និង"គម្រោងបង្កើនសមត្ថភាពបោសសម្អាតកាកសំណល់ជាតិផ្ទុះពីសង្គ្រាមដល់អង្គការCMAC ដំណាក់កាលទី២" ផ្តល់ជូនដល់អង្គការJMAS។

ចាប់តាំងពីឆ្នាំ២០០៧មក អង្គការFIDR បាននឹងកំពុងបន្តការងាររបស់ខ្លួននៅក្នុងស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ហើយក៏បាននឹងកំពុងបន្តសកម្មភាពរបស់ខ្លួនក្នុងការជួយអភិវឌ្ឍជនបទសម្រាប់រយៈពេលវែងផងដែរ។ នៅក្នុងឆ្នាំ២០១១ ដោយទទួលបានការកោតសរសើរពីកិច្ចខិតខំប្រឹងប្រែង អង្គការFIDR បានពង្រីកតំបន់គោលដៅគម្រោងរបស់ខ្លួននៅកម្ពុជា ទៅកាន់ភូមិចំនួន៣៩ នៃឃុំចំនួន៥ ក្នុងស្រុកចំនួន២ ខេត្តកំពង់ឆ្នាំង ដោយបានចាប់ដៃគូសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

គម្រោងនេះ បានចាប់ផ្តើមនៅឆ្នាំ២០១៤ ដើម្បីបង្កើនផលិតភាពនៃការធ្វើស្រែ ពិពិធកម្មនៃការដាំបន្លែនិងចិញ្ចឹមសត្វ កែលម្អស្ថានភាពផ្នែកអាហាររូបត្ថម្ភសម្រាប់កុមារ និងបង្កើតបណ្តាញទំនាក់ទំនងរវាងកសិករនិងកសិករនៅក្នុងភូមិគោលដៅចំនួន៣៩ ក្នុងស្រុករលាប្អៀរ និងស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង។ នៅក្នុងដំណាក់កាលទី៣នៃគម្រោងនេះ អង្គការFIDR ត្រូវបានផ្តល់ជូនថវិកាប្រមាណជាង ២២ម៉ឺនដុល្លារអាមេរិកពីរដ្ឋាភិបាលជប៉ុន។ យើងសង្ឃឹមថា គម្រោងនេះ នឹងជះឥទ្ធិពលយ៉ាងធំធេងបន្តទៀតដើម្បីអោយប្រជាជនក្នុងតំបន់គោលដៅមានឯករាជ្យភាពបន្ទាប់ពីបញ្ចប់គម្រោងនេះទៅ។

តាមរយៈជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន អង្គការJMAS បានបន្តអនុវត្តសកម្មភាពរបស់ខ្លួនជាបន្តបន្ទាប់រហូតដល់១៣ខេត្ត ចាប់តាំងពីឆ្នាំ២០០២។ អង្គការJMAS ទទួលបានជោគជ័យក្នុងការបន្តធ្វើសកម្មភាពរបស់ខ្លួនជាច្រើនរួមមាន៖ ការបោសសម្អាតមីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ក៏ដូចជាការផ្ទេរបច្ចេកទេសជាច្រើនដល់អង្គការCMAC ដែលជាការរួមចំណែកដ៏ធំធេងក្នុងការកសាងសន្តិភាពនៅកម្ពុជា។

រដ្ឋាភិបាលជប៉ុន នឹងផ្តល់ជូនថវិកាប្រមាណជា ៥៤ម៉ឺនដុល្លារអាមេរិក សម្រាប់គម្រោងឆ្នាំទី២ នៃគម្រោងផែនការ៣ឆ្នាំ។ ខ្ញុំសង្ឃឹមថា គម្រោងនេះ នឹងបង្កើនសមត្ថភាពចំណេះដឹងជំនាញ និងបច្ចេកទេសសុវត្ថិភាពដល់សមាជិកក្រុមCMAC ដើម្បីបង្កើនការបោសសម្អាតកាកសំណល់ជាតិផ្ទុះពីសង្គ្រាមទូទាំងប្រទេសកម្ពុជា។ តាមរយៈគម្រោងនេះ ខ្ញុំសង្ឃឹមថា ប្រជាជននឹងរួចផុតពីភាពភ័យខ្លាចពីតំបន់ដែលមានគ្រាប់មីន ហើយគម្រោងនេះ នឹងធ្វើអោយស្ថានភាពជីវិតរបស់ពួកគេមានលំនឹង និងមានលក្ខណៈល្អប្រសើរ ក៏ដូចជាបន្តការអភិវឌ្ឍសហគមន៍ក្នុងតំបន់។

ជាចុងក្រោយនេះ ជំនួយឧបត្ថម្ភសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ត្រូវបានផ្តល់ជូនសម្រាប់គម្រោងអភិវឌ្ឍផ្នែកសង្គមកិច្ច និងសេដ្ឋកិច្ច ដែលជាគុណប្រយោជន៍សម្រាប់ប្រជាជននៅតាមកំរិតមូលដ្ឋាន។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា គម្រោងទាំងពីរដែលបានចុះហត្ថលេខានៅថ្ងៃនេះ នឹងជួយពង្រឹងបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

**សូមអរគុណ!**